# ច្បាប់
# ស្តីពី
# អន្តោប្រវេសន៍

# ច្បាប់

## ស្តីពី

## អន្តោប្រវេសន៍

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

មាត្រា ១ ._

ច្បាប់នេះមានគោលដៅគ្រប់គ្រងជនបរទេសគ្រប់រូប ដែលមកស្នាក់នៅលើទឹកដីនៃព្រះ_រាជាណាចក្រកម្ពុជា ។

មាត្រា ២ ._

ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានបីសអើង ទោះបីជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។

មាត្រា ៣ ._

ច្បាប់នេះត្រូវអនុវត្តចំពោះជនបរទេសគ្រប់រូប លើកលែងតែក្នុងករណីដែលត្រូវអនុវត្តតាមវិធាននៃច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ទោះបីជាជននោះបានចូលមកតាំងលំនៅមុនពេលដែលច្បាប់នេះចូលជាធរមានហើយក៏ដោយ ។

មាត្រា ៤ ._

អនុលោមតាមលក្ខខណ្ឌនៃប្រវេសន៍ និងការស្នាក់អាស្រ័យនៅប្រទេសកម្ពុជា ជនបរ_ទេស ត្រូវចែកជាបីប្រភេទគឺ ៖

១_ ជនបរទេសមិនមែនអន្តោប្រវេសន្ត

២_ ជនបរទេសអន្តោប្រវេសន្ត

៣_ ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ។

មាត្រា ៥ ._

ការគ្រប់គ្រងជនបរទេសជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ ក្រសួងនេះត្រូវមានស្ថាប័នមួយដើម្បីទទួលខុសត្រូវកិច្ចការអន្តោប្រវេសន៍ ។

មាត្រា ៦ ._

ក្រសួងមហាផ្ទៃត្រូវកំណត់អំពីបែបបទនៃការចុះបញ្ជី ការផ្តល់ ការត្រួតពិនិត្យបណ្ណស្នាក់នៅ ទិដ្ឋាការចេញ ទិដ្ឋាការចូល លិខិតបើកផ្លូវ និងលិខិតឆ្លងដែន ឬឯកសារដែលមានតម្លៃស្មើគ្នាសំរាប់ជនបរទេស ។

## ជំពូកទី ២
## ជនបរទេសមិនមែនអន្តោប្រវេសន្ត

មាត្រា ៧ ._

ជនបរទេសមិនមែនអន្តោប្រវេសន្តគឺ ៖

១_ ភ្នាក់ងារដែលបំពេញការនៅស្ថានទូតបរទេស ឬស្ថានកុងស៊ុលបរទេស ឬស្ថានតំណាងបេសកកម្មបរទេស អ្នកជំនាញការអន្តរជាតិនិងជនផ្សេងៗទៀតដែលចូលមកព្រះរាជាណាចក្រកម្ពុជាតាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយរាប់ទាំងក្រុមគ្រួសារ និងបុគ្គលិករបស់គេក្នុងរយៈពេលដែលគេស្នាក់អាស្រ័យនៅ ។

២_ ទាហាន មន្ត្រី អ្នករដ្ឋការ និយោជិត និងភ្នាក់ងារបរទេស និស្សិតព្រមទាំងគ្រួសារដែលចូលមកព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

៣_ អ្នកធ្វើដំណើរឆ្លងកាត់ ជាអ្នករង់ចាំមធ្យោបាយធ្វើដំណើរមុនពេលចេញដំណើរឆ្ពោះទៅកាន់ទីដៅចុងក្រោយរបស់ខ្លួន ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យនៅមិនត្រូវលើសពីមួយសប្តាហ៍ លើកលែងតែក្នុងករណីប្រធានសក្តិ ។

៤_ អ្នកទេសចរដែលមានសំបុត្រត្រឡប់ទៅវិញ ហើយរយៈពេលស្នាក់អាស្រ័យត្រូវកំណត់ដោយអនុក្រឹត្យ ។

៥_ អ្នកតំណាងពាណិជ្ជកម្ម ធនាគារ អ្នកប្រកបមុខរបរផ្សេងៗទៀត ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងអំពីកិច្ចការខាងលើ ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យមិនអាចលើសពី ៣ ខែ ។ ក្នុងករណីមានហេតុផលចាំបាច់ ការស្នាក់អាស្រ័យនៅនេះ អាចបន្តទៀតបានរយៈពេល ៣ ខែ ជាអតិបរមា តាមការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

៦_ ជនបរទេសរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រ_កម្ពុជា ដែលបានទទួលការអនុញ្ញាតឱ្យឆ្លងកាត់ព្រំប្រទល់ច្រើនដង ឬមួយដងមួយកាល ។ លក្ខខ័ណ្ឌផ្សេងៗក្នុងការអនុវត្តចំណុចទី ៦ មាត្រា ៧ នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៧_ អ្នកធ្វើដំណើរ កងនាវិក និងយានិក ដែលមកសំចតយកស្បៀងនៅតាមកំពង់ផែសមុទ្រ និងតាមព្រលានយន្តហោះ ។

៨_ ជនបរទេសដែលមកធ្វើការនេសាទនៅតាមឆ្នេរសមុទ្រនៃព្រះរាជាណា_ចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ៨ ._

ជនបរទេសមិនមែនអន្តោប្រវេសន្តអាចស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន :

១_ ត្រូវមានការអនុញ្ញាតចូលជាមុនពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញា_ធរទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ឬតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។ ចំពោះអ្នកដំណើរឆ្លងកាត់ កងនាវិក យានិក ការអនុញ្ញាតនេះនឹងត្រូវផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលគេចេញពីនាវា ឬព្រលានយន្តហោះ ។

២_ ត្រូវនាំមកជាមួយនូវលិខិតឆ្លងដែនរបស់ខ្លួន ឬឯកសារណាមួយដែលមានតម្លៃស្មើ ដែលមានចុះទិដ្ឋាការចូលដោយអាជ្ញាធរ ដូចមានកំណត់នៅវាក្យខ័ណ្ឌទីមួយខាងលើ ។

៣_ ត្រូវបង់ថ្លៃទិដ្ឋាការ អាករព្រលានយន្តហោះឬកំពង់ផែ ។ លក្ខខ័ណ្ឌនៃការបង់ថ្លៃនិងអាករនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៩ ._

ជនបរទេសមិនមែនអន្តោប្រវេសន្តណាដែលមិនបានបំពេញតាមលក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា ៨ នៃច្បាប់នេះ មិនត្រូវអនុញ្ញាតឱ្យចូលមកព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណីដែលមានការអនុញ្ញាតផ្សេងពីនេះរបស់រាជរដ្ឋាភិបាល ។

ក្នុងករណីប៉ះពាល់ដល់សន្តិសុខជាតិ អាជ្ញាធរមានសមត្ថកិច្ចអាចហាមឃាត់មិនឱ្យចូលបាន ទោះបីជនបរទេសមិនមែនអន្តោប្រវេសន្តនោះបានបំពេញលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ ហើយក៏ដោយ ។

# ជំពូកទី ៣
## ជនបរទេសអន្តោប្រវេសន្ត

មាត្រា ១០ ._

ជនបរទេសដែលចាត់ទុកជាអន្តោប្រវេសន្តគឺ :

១_ ជនបរទេសដែលមកដល់ព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ដើម្បីស្នាក់នៅរយៈពេលយូរ ឬដើម្បីប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗដែលទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម សេវា ឬកសិកម្ម ។

២_ ជនបរទេសដែលគ្មានរាប់ចូលក្នុងប្រភេទណាមួយ ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ។

មាត្រា ១១ ._

អាចទទួលឱ្យស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេសអន្តោប្រវេសន្តណាដែលបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨នៃច្បាប់នេះ ហើយលើសពីនេះត្រូវបំពេញកាតព្វកិច្ចដូចតទៅ :

១_ បង្ហាញនូវសម្បទាមានផលប្រយោជន៍ដល់សេដ្ឋកិច្ច ឬសង្គមកិច្ច ឬវិទ្យាសាស្ត្របច្ចេកទេស ឬវប្បធម៌ សំរាប់ព្រះរាជាណាចក្រកម្ពុជា ។

២_ តំកល់ប្រាក់ធានាតាមចំនួនសមស្រប សំរាប់បង់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់ទៅវិញឬមាតុភូមិនិវត្តន៍ដោយថាហេតុនិងមានប្រាក់ធានាថាអាចរស់នៅបានដោយសារទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។

ចំនួនទឹកប្រាក់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

៣_ មានកាយសម្បទាបំពេញវិជ្ជាជីវៈខ្លួនបាន ដោយមានការបញ្ជាក់ពីគ្រូពេទ្យនៃប្រទេសដែលអន្តោប្រវេសន្តចេញមក និងមានកិច្ចសន្យាការងារជាលាយលក្សណ៍អក្សរ ។

៤_ មានលិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមរបស់ខ្លួន ។

៥_ ទោះបីជនបរទេសអន្តោប្រវេសន្ត បានបំពេញលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះហើយក៏ដោយ ក៏ជនគ្រប់រូបទាំងនោះត្រូវបំពេញឱ្យបាននូវលក្ខខណ្ឌផ្នែកសន្តិសុខដែលព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមាន ។

មាត្រា ១២ .-

ការទទួលស្គាល់ជនបរទេសណាម្នាក់ជាជនបរទេសអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៣ .-

ជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តដែលត្រូវបានទទួលឱ្យចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ហាញខ្លួននៅប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន្ត ទាំងពេលមកដល់ និងពេលចេញដំណើរទៅវិញ ។ ច្រកព្រំដែន ឬចំណុចចេញចូលរបស់ជនបរទេសត្រូវកំណត់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ។

មាត្រា ១៤ .-

ជនបរទេសអន្តោប្រវេសន្តត្រូវទៅបង្ហាញខ្លួនក្នុងរយៈពេល ៤៨ ម៉ោង ក្រោយពេលមកដល់ នៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាល ខេត្ត ក្រុង ដែលខ្លួនមានបំណងស្នាក់នៅដើម្បីធ្វើពាក្យសុំប័ណ្ណស្នាក់នៅ ។ បង្កាន់ដៃសំគាល់នឹងត្រូវផ្តល់ភ្លាមជូនសាមីខ្លួនក្រោយពីបានទទួលពាក្យសុំនេះ ។

មាត្រា ១៥ .-

ក្នុងករណីដែលមានការផ្លាស់ប្តូរលំនៅដ្ឋាន ជនបរទេសអន្តោប្រវេសន្តត្រូវសុំការបញ្ជាក់នៅលើប័ណ្ណស្នាក់នៅរបស់ខ្លួន នៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាលខេត្ត ក្រុងដែលខ្លួនមានលំនៅដ្ឋានមុនពេលខ្លួនចេញដំណើរ ។ ជនបរទេសអន្តោប្រវេសន្តត្រូវបំពេញបែបបទដូចខាងលើនេះ ក្នុងរយៈពេល ៤៨ ម៉ោងបន្ទាប់ពីបានទៅដល់លំនៅដ្ឋានថ្មី ។

មាត្រា ១៦ .-

ប័ណ្ណស្នាក់នៅនេះត្រូវបង្ហាញនៅពេលដែលមានការដែកឆេរពីអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។ ប័ណ្ណស្នាក់នៅនេះអាចដកហូតបានពីសាមីជនណាដែលមិនបានគោរពតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដកហូតប័ណ្ណស្នាក់នៅ ជនបរទេសអន្តោប្រវេសន្តត្រូវចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលប្រាំពីរថ្ងៃ ។ ក៏ប៉ុន្តែតាមកាលៈទេសៈជាក់ស្តែង រយៈពេលនេះអាចកែប្រែបានដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ហើយរយៈពេលបន្តមិនត្រូវលើសពី ៣ ខែ ។

ការឈប់ទទួលស្គាល់ជនបរទេសណាម្នាក់ជាជនបរទេសអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៧ ..

ជាគោលការណ៍ ជនបរទេសអាចធ្វើចរាចរបានដោយសេរីនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ក៏ប៉ុន្តែក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចដាក់បញ្ញត្តិហាមឃាត់ចរាចរជនបរទេស និងហាមឃាត់ជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តទាំងអស់មិនឱ្យចូល ឬស្នាក់អាស្រ័យនៅក្នុងតំបន់ ឬចាកចេញឆ្ងាយពីតំបន់ ឬកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៨ ..

ម្ចាស់ ឬអ្នកកាន់កាប់លំនៅឋានគ្រប់ប្រភេទ ត្រូវជូនដំណឹងក្នុងរយៈពេល ២៤ ម៉ោង ដល់ស្ថាប័ននគរបាលមានសមត្ថកិច្ចពីវត្តមាននៃជនបរទេសអន្តោប្រវេសន្ត ឬមិនមែនអន្តោប្រវេសន្តដែលបានមកស្នាក់នៅ ។

មាត្រា ១៩ ..

ការទទួលជនបរទេសឱ្យធ្វើការត្រូវអនុវត្តតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងមហាផ្ទៃមានសិទ្ធិត្រួតពិនិត្យប័ណ្ណការងាររបស់ជនបរទេសនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន គ្រឹះស្ថាននានា ដោយសហការជាមួយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

មាត្រា ២០ ..

ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ត្រូវជូនដំណឹងទៅក្រសួងមហាផ្ទៃអំពីមរណភាពនិងការបាត់ខ្លួនរបស់ជនបរទេសអន្តោប្រវេសន្ត ដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ២១ ..

ប័ណ្ណស្នាក់នៅចេញឱ្យលើកដំបូងមានសុពលភាពសំរាប់រយៈពេលពីរឆ្នាំ ។ ប័ណ្ណស្នាក់នៅនេះអាចសុំបន្តការប្រើប្រាស់បានរាល់ពីរឆ្នាំម្តង ។ ពាក្យសុំប័ណ្ណស្នាក់នៅថ្មី ឬសុំបន្តរយៈពេលប្រើប្រាស់ត្រូវធ្វើនៅចំពោះមុខអាជ្ញាធរដូចបានកំណត់ត្រង់មាត្រា ១៥ នៃច្បាប់នេះ ។ ហួសកំណត់ខាងលើនេះ ម្ចាស់ប័ណ្ណស្នាក់នៅដែលមិនបានសុំប័ណ្ណស្នាក់នៅថ្មី ឬសុំបន្តរយៈពេលប្រើប្រាស់ត្រូវចាត់ទុកថាស្ថិតនៅក្នុងស្ថានភាពមិនត្រឹមត្រូវតាមច្បាប់ ។ ក្រសួងមហាផ្ទៃត្រូវកំណត់ដោយប្រកាសរបស់ក្រសួង នូវវិធានការអនុវត្តទាក់ទងនឹងការគ្រប់គ្រង ការធ្វើប័ណ្ណស្នាក់នៅ ការសុំនិងលក្ខខណ្ឌនានា ដែលត្រូវអនុវត្តក្នុងវិស័យនេះ ។ ជនបរទេសអន្តោប្រវេសន្តត្រូវបង់អាករសំរាប់ការចេញប័ណ្ណស្នាក់នៅដើមឬខុតិយតា ឬឯកសារដែលមានតម្លៃស្មើគ្នា តាមការកំណត់របស់អនុក្រឹត្យ ។

**មាត្រា ២២ ._**

ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវត្រួតពិនិត្យជនបរទេសទាំងអស់ ដែលបានតាំងទីលំនៅ ឬទើបនឹងមកតាំងទីលំនៅក្នុងដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២៣ ._**

ជនបរទេសអន្តោប្រវេសន្តណាដែលមានបំណងចាកចេញពីព្រះរាជាណាចក្រកម្ពុជាមួយរយៈពេល ត្រូវសុំការអនុញ្ញាតចេញ និងវិលមកវិញពីក្រសួងមហាផ្ទៃ ។ ជាគោលការណ៍ រយៈពេលនៃការស្នាក់អាស្រ័យនៅបរទេសមិនត្រូវលើសពី បីខែឡើយ ។ ប៉ុន្តែរយៈពេលនេះអាចពន្យាបានរហូត ប្រាំមួយខែ ប្រសិនបើមានមូលហេតុសមហេតុសមផល ។ អាករលើការផ្តល់ការអនុញ្ញាតចេញ និងវិលមកវិញត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៤ ._**

ក្នុងករណីត្រឡប់មកវិញលើសរយៈពេលអនុញ្ញាត សាមីខ្លួនត្រូវធ្វើពាក្យសុំទិដ្ឋាការចូល ហើយចាត់ទុកថា ជននោះជាជនបរទេសអន្តោប្រវេសន្តមកថ្មី ។

## ជំពូកទី ៤
## ជនបរទេសអន្តោប្រវេសន្ត
## ជាអ្នកវិនិយោគឯកជន

**មាត្រា ២៥ ._**

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន គឺជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើវិនិយោគក្នុងក្របខ័ណ្ឌនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦ ._**

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ចែកចេញជាពីរប្រភេទគឺ ៖

១_ ជនបរទេសដែលចូលមកកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ

២_ ជនបរទេសដែលបានទទួល " លិខិតអនុញ្ញាតឱ្យវិនិយោគ " ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួចហើយ ។

មាត្រា ២៧ .-

ជនបរទេសដែលចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ ត្រូវបំពេញល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងជំពូកទី ៣ ស្តីពីជនបរទេសអន្តោប្រវេសន្ត លើកលែងតែសុពលភាពសំរាប់រយៈពេលស្នាក់នៅបណ្តោះអាសន្ន គឺសំរាប់រយៈពេលមួយឆ្នាំ ។ ក្រោយរយៈពេលមួយឆ្នាំនៃការស្នាក់នៅ ក្នុងករណីដែលមិនអាចមានលទ្ធភាពធ្វើវិនិយោគបានលើវិស័យណាមួយទេ ជនបរទេសនោះអាចដកប្រាក់តម្កល់នានាវិញបាន ហើយមិនអាចបន្តឱ្យស្នាក់នៅបានទៀតឡើយ ។

មាត្រា ២៨ .-

ជនបរទេសដែលបានទទួល " លិខិតអនុញ្ញាតឱ្យវិនិយោគ " ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមទាំងគ្រួសារផ្ទាល់ខ្លួន នឹងបានទទួលការអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាអចិន្ត្រៃយ៍ ឬតាមរយៈពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យវិនិយោគ និងមានសិទ្ធិសុំកាន់ឯកសារធ្វើដំណើររបស់ព្រះរាជាណាចក្រកម្ពុជា ។

បែបបទនៃការអនុវត្តមាត្រា ២៨ នេះ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ទោសបញ្ញត្តិ

មាត្រា ២៩ .-

ជនបរទេសរូបណាដែលគ្មានការអនុញ្ញាត ហើយចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលបលាក់ បន្លំ ឬ ដោយល្បិចផ្សេងទៀតដែលផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់គុកពី បីខែ ដល់ ប្រាំមួយខែ មុននឹងត្រូវបណ្តេញចេញ ។

ត្រូវផ្តន្ទាទោសដូចគ្នានឹងជនល្មើស ចំពោះជនណាដែលផ្តល់ជំនួយ ឬជួយលាក់បាំងក្នុងការបញ្ចូលជនបរទេសដែលគ្មានការអនុញ្ញាតមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណា ដែលជាអ្នកសមគំនិត ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់គុកពី ប្រាំមួយខែ ដល់ មួយឆ្នាំ ។

មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ។

មធ្យោបាយសម្ភារៈប្រើសំរាប់ប្រព្រឹត្តបទល្មើសត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋដោយតុលាការ។

មាត្រា ៣០ ._

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ៥០.០០០ រៀល ដល់ ១.០០០.០០០ រៀល ចំពោះជនបរទេសណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៤_១៥_១៦_១៧_២១ និង ២៣ នៃច្បាប់នេះ ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០១ រៀល ដល់ ២.០០០.០០០ រៀល ។

មាត្រា ៣១ ._

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០ រៀល ដល់ ៣០.០០០ រៀល ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៨ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ៣០.០០១ រៀល ដល់ ៦០.០០០ រៀល ។

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០០.០០០ រៀល ដល់ ៥០០.០០០ រៀល ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៩ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់គុកពី មួយខែ ដល់បីខែ ។

មាត្រា ៣២ ._

ជនណាដែលធ្វើការកោស លុប សរសេរត្រួត ក្លែង ឬឱ្យគេខ្ចី ឬមួយក៏សរសេរឈ្មោះក្លែងក្លាយនៅក្នុងប័ណ្ណស្នាក់នៅ ប័ណ្ណការងារ កិច្ចសន្យាការងារ ឬមួយក៏ប្រើប្រាស់ឯកសារទាំងនោះដែលមានឈ្មោះផ្សេងពីឈ្មោះខ្លួន ឬធ្វើបណ្តឹងក្លែងបន្លំសុំឯកសារដូចខាងលើ ត្រូវផ្តន្ទាទោសដាក់គុកពី ប្រាំឆ្នាំ ដល់ ដប់ប្រាំឆ្នាំ ។

អ្នកសមគំនិតត្រូវផ្តន្ទាទោសដូចគ្នា ។

មាត្រា ៣៣ ._

ការផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ដែលមានចែងក្នុងបញ្ញត្តិនៃច្បាប់នេះជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៣៤ .

ក្រៅពីមូលទោសដែលមានចែងក្នុងច្បាប់នេះ ត្រូវមានអនុទោសបន្ថែមទៀតគឺការបណ្តេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៦
## ការបណ្តេញចេញ

**មាត្រា ៣៥**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសអន្តោប្រវេសន្តណាដែលរំលោភលើបញ្ញត្តិច្បាប់អន្តោប្រវេសន្ត ។

**មាត្រា ៣៦ ._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសដែល ៖

១_ មានអាកប្បកិរិយានិងសកម្មភាពគ្រោះថ្នាក់ដល់សន្តិសុខជាតិនៃព្រះរាជាណាចក្រកម្ពុជា ឬ

២_ ក្រសួងមានសមត្ថកិច្ចមានភស្តុតាងជាក់លាក់ថាជននោះជាអ្នកប្រឆាំងនឹងសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ឬ

៣_ មកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ ។

**មាត្រា ៣៧ ._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសណាដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ។

**មាត្រា ៣៨ ._**

សេចក្តីសំរេចបណ្តេញចេញត្រូវអនុវត្តភ្លាម ចាប់ពីថ្ងៃចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ សាមីខ្លួនមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល ២ ខែ ។

**មាត្រា ៣៩ ._**

ការបណ្តេញចេញត្រូវអនុវត្តក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ ក្រោយពីសេចក្តីសំរេចចេញជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែមានសាលក្រមផ្អាកការអនុវត្តពីតុលាការ ។

# ជំពូកទី ៨

# អវសានបញ្ញត្តិ

**មាត្រា ៤០ .-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១

ភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

សឺន ស៊ូប៊ែរ្ត